**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៣-អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១៖**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបចំនួន ៦.០០០ហិកតា (ប្រាំមួយពាន់ហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តសៀមរាប និងខេត្តព្រះវិហារ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **លី ឈួង សំណង់ & អាហារ៍ណនីហារ៍ណ** ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ រយៈពេល ៧០ឆ្នាំ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៣០៧ សជណ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១២ ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

- ត្រូវបាននិរាករណ៍លិខិតលេខ ៦៣១ សជណ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។
- ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

## ផែនទីដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ របស់ក្រុមហ៊ុន លី ឈួង សំណង់ & អាហារ៉ណា នីហារ៉ណ
## ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តសៀមរាប លើផ្ទៃដីចំនួន ៦០០០ ហិកតា




ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...
ចុះថ្ងៃទី .១៦...... ខែ ... ឆ្នាំ ២០១២
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
អនុរដ្ឋលេខាធិការ

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...៣០៩... សជណ
ចុះថ្ងៃទី ...២១... ខែ ...មិនា... ឆ្នាំ ២០១២
ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

**សញ្ញាសំគាល់**

- ទីតាំងដីវិនិយោគ
- ព្រំប្រទល់ខេត្ត
- ផ្លូវលំ
- ស្ទឹង. អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព

| ID | N | X | Y |
|---|---|---|---|
| 1 | A | 445124 | 1527030 |
| 2 | B | 444031 | 1527512 |
| 3 | C | 440994 | 1527549 |
| 4 | D | 440957 | 1529123 |
| 5 | E | 440031 | 1529178 |
| 6 | F | 428042 | 1523531 |
| 7 | G | 428036 | 1520746 |

N W E S

មាត្រដ្ឋាន 1:80,000

0 1 2 Kilometers